**Cambodia REDD+ National Programme**
UNDP PROJECT No. 00078446
(#40, Preah Norodom Blvd, Khan Daun Penh, Phnom Penh, Kingdom of Cambodia, 3rd Floor)

# ឯកសារទស្សនទាន
## ស្តីពីការបណ្តុះបណ្តាលទស្សនទានយេនឌ័រ និងរេដបូកសម្រាប់ ក្រុមបច្ចេកទេសរេដបូក និងក្រុមប្រឹក្សាយោបល់រេដបូក

## ១-សេចក្តីផ្តើម

ការសិក្សារួមគ្នាថ្មីមួយរវាង UN-REDD/LEAF/WOCAN អំពីយេនឌ័រ និងរេដបូកនៅកម្ពុជា បានកំណត់ឧបសគ្គនៃការរួមបញ្ចូលស្រ្តីទាំងនៅថ្នាក់ស្ថាប័ន គោលនយោបាយ និងថ្នាក់សហគមន៍ ឧទាហរណ៍ ការខ្វះតំណាងរបស់ស្រ្តី។ ឆ្លើយតបទៅនឹងអនុសាសន៍ដែលបានមកពីការសិក្សារួមគ្នានេះ ក្រុមការងាររេដបូកបានស្នើឲ្យលេខាធិការដ្ឋានរេដបូកធ្វើការសិក្សាពីជម្រើសក្នុងការបង្កើតក្រុមយេនឌ័រ។ នៅខែសីហា ឆ្នាំ២០១៤ ក្រុមយេនឌ័រ ដោយមានសមាជិកចំនួន៤ រូបជាមន្ត្រីមកពីក្រសួងបរិស្ថាន ក្រសួងកិច្ចការនារី រដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្រុមយេនឌ័រនេះ នឹងធ្វើការលើកកម្ពស់ចំណេះដឹងអំពីយេនឌ័រ និងគោលគំនិតនៃការផ្តល់សិទ្ធិអំណាច និងបញ្ហារបស់ស្រ្តី ក្នុងចំណោមសមាជិកនៃក្រុមការងាររេដបូក ក្រុមប្រឹក្សាយោបល់រេដបូក និងក្រុមបច្ចេកទេសរេដបូកទាំងបួន និងផ្តល់យោបល់ទៅលើបញ្ហាយេនឌ័រ ដើម្បីធានាថាយុទ្ធសាស្រ្តរេដបូកជាតិ និងគោលការនៃការអនុវត្ត បានគិតពិចារណា និងឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ។

ក្រុមយេនឌ័របានរៀបចំកិច្ចប្រជុំ និងបានរៀបចំផែនការការងារ និងសុំការអនុម័តពីក្រុមការងាររេដបូកកម្ពុជា។ អនុវត្តតាមផែនការការងារនេះ វគ្គបណ្តុះបណ្តាលស្តីពីទស្សនទានយេនឌ័រ និងរេដបូក សម្រាប់សមាជិកក្រុមយេនឌ័របានរៀបចំនៅខែវិច្ឆិកា ឆ្នាំ២០១៤ នៅខេត្តកំពត។ ជាជំហ៊ានបន្ទាប់សមាជិកក្រុមយេនឌ័រនឹងផ្តល់ការបណ្តុះបណ្តាលស្តីពីទស្សនទានយេនឌ័រ និងរេដបូកជូនដល់ក្រុមបច្ចេកទេសរេដបូកទាំងបួនក្រុម និងក្រុមប្រឹក្សាយោបល់រេដបូក។

## ២-គោលបំណង

លើកកម្ពស់ចំណេះដឹងស្តីអំពីទស្សនទានយេនឌ័រ និងរេដបូក និងពង្រឹងសមត្ថភាពក្រុមបច្ចេកទេសរេដបូកទាំងបួនក្រុម និងក្រុមប្រឹក្សាយោបល់រេដបូក ដើម្បីជួយដល់ការបញ្ជ្រាបបញ្ហាយេនឌ័រ និងធានាថាយុទ្ធសាស្រ្តរេដបូកជាតិក៏ដូចជាគោលការណ៍ណែនាំការអនុវត្ត មានសមធ៌មយេនឌ័រ និងមានការឆ្លើយតបនឹងបញ្ហាយេនឌ័រ។

## ៣-ការរំពឹងទុក

តាមរយៈសកម្មភាពនៃវគ្គបណ្តុះបណ្តាល ក្រុមបច្ចេកទេស និងក្រុមប្រឹក្សាយោបល់រេដបូក បានយល់ដឹងពី ទស្សនទានយេនឌ័រ និងរេដបូក ក៏ដូចជាបញ្ជីផ្ទៀងផ្ទាត់យេនឌ័រ។ លើសពីនេះ ក្រុមបច្ចេកទេស និងក្រុមប្រឹក្សាយោបល់រេដបូក អាចមានសមត្ថភាពប្រើប្រាស់ចំណេះដឹងស្តីពីទស្សនទានយេនឌ័រ និងបញ្ជីផ្ទៀងផ្ទាត់បញ្ហាយេនឌ័រ ដើម្បីត្រួតពិនិត្យការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ និងធ្វើឲ្យប្រាកដថា យុទ្ធសាស្ត្ររេដបូកជាតិ បានដាក់គិតគូរ និងដាក់បញ្ចូលបញ្ហាយេនឌ័របានសមស្រប។

## ៤-សកម្មភាព

- កិច្ចប្រជុំរវាងក្រុមយេនឌ័រ និងលេខាធិការដ្ឋានរេដបូក នឹងត្រូវរៀបចំ ដើម្បីពិភាក្សាពីផែនការការងារ និងការបែងចែកភារកិច្ច ក្នុងរៀបចំវគ្គបណ្តុះបណ្តាលស្តីពីទស្សនទានយេនឌ័រ និងរេដបូកនេះ។
- ក្រុមយេនឌ័រទទួលខុសត្រូវ រៀបចំឯកសារ វិធីសាស្ត្រ និងបទបង្ហាញសម្រាប់វគ្គបណ្តុះបណ្តាល ដែលនឹងធ្វើឡើងសម្រាប់ក្រុមបច្ចេកទេស និងក្រុមប្រឹក្សាយោបល់រេដបូក។
- លេខាធិការដ្ឋានរេដបូក រៀបចំលិខិតអញ្ជើញ និងទំនាក់ទំនងជាមួយ UNDP-CO ដើម្បីផ្តល់ការរៀបចំថវិកា និងគាំទ្រភស្តុភារ ក៏ដូចជាទីកន្លែងនៃវគ្គបណ្តុះបណ្តាល។

## ៥-លទ្ធផល

- វគ្គបណ្តុះបណ្តាលចំនួន២លើកបានរៀបចំ និងមានសិក្ខាកាមសរុបចំនួន ៤២នាក់បានចូលរួម។
- បានផ្តល់ចំណេះដឹងស្តីពី ទស្សនទានយេនឌ័រ និងរេដបូក និងបញ្ជីផ្ទៀងផ្ទាត់បញ្ហាយេនឌ័រ ដល់ក្រុមបច្ចេកទេស និងក្រុមប្រឹក្សាយោបល់រេដបូក។
- ក្រុមបច្ចេកទេស និងក្រុមប្រឹក្សាយោបល់រេដបូក មានសមត្ថភាពប្រើប្រាស់ ទស្សនទានយេនឌ័រ និងបញ្ជីផ្ទៀងផ្ទាត់បញ្ហាយេនឌ័រ ដើម្បីត្រួតពិនិត្យការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ និងធានាថាបញ្ហាយេនឌ័របានដាក់បញ្ចូល។

## ៦-ពេលវេលា និងទីកន្លែង

វគ្គបណ្តុះបណ្តាលនឹងរៀបចំជាពីរលើកៈ

- លើកទី១ នៅខេត្តព្រះសីហនុ នៅថ្ងៃទី១ ដល់ ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ (បានអនុវត្តរួច)
- លើកទី២ នៅខេត្តសៀមរាប នៅថ្ងៃទី១១ ដល់ ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៥ ។

## ៧-របៀបវារៈ

| ពេលវេលា | ប្រធានបទសិក្សា | អ្នកសម្របសម្រួល |
|---|---|---|
| | ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ | |
| 08:00-08:30 | ចុះឈ្មោះសិក្ខាកាម | ក្រុមយេនឌ័រ |
| 08:30-08:45 | មតិចាប់អារម្មណ៍ថ្នាក់ដឹកនាំក្នុងពិធីបើកវគ្គបណ្តុះបណ្តាល | លោក គឹម ណុង |
| 08:45-09:00 | សេចក្តីផ្តើមនៃវគ្គបណ្តុះបណ្តាល<br>• គោលបំណងនៃវគ្គបណ្តុះបណ្តាល<br>• ការរៀបចំក្រុមការងារ | លោក លន់ គឹមហ៊ី |
| 09:00-09:45 | បទបង្ហាញស្តីពីទស្សនទានយេនឌ័រ<br>• សំណួរ និង ចម្លើយ | លោកស្រី ថាច់ ផាន់ណាឌី |
| 09:45-10:00 | សម្រាកអាហារសម្រន់ | |
| 10:00-10:30 | ទស្សនាវីដេអូ ស្តីពីយេនឌ័រនិងរេដបូក<br>• សំណួរ និង ចម្លើយ | លោកសុខ ពិសិដ្ឋ |
| 10:30-11:30 | បទបង្ហាញស្តីពីសមធម៌យេនឌ័រ និងការបង្កើនសិទ្ធស្រ្តី<br>• សំណួរ និង ចម្លើយ | លោកសុខ ពិសិដ្ឋ |
| 11:30- | សម្រាកអាហារថ្ងៃត្រង់ | |
| 14:00-15:30 | បទបង្ហាញស្តីពីការវិភាគយេនឌ័រ<br>• ក្រុមពិភាក្សា | លោកសៅ ចន្ទ្រាម៉ាលី |
| 15:30-15:45 | សម្រាកអាហារសម្រន់ | |
| 15:45-16:30 | បង្ហាញលទ្ធផលក្រុមពិភាក្សា | តំណាងក្រុមនីមួយៗ |
| 16:30-17:00 | • សង្ខេបលទ្ធផលសិក្សាថ្ងៃទី១<br>• ការវាយតម្លៃប្រចាំថ្ងៃ(ថ្ងៃទី១) | លោក លន់ គឹមហ៊ី<br>ក្រុមការងារ |
| | ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៥ | |
| 08:00-08:30 | • រាយការណ៍ចំណុចសំខាន់ៗដែលបានសិក្សាថ្ងៃទី១<br>• រាយការណ៍លទ្ធផលវាយតម្លៃប្រចាំថ្ងៃ | ក្រុមការងារ |
| 08:30-09:45 | បទបង្ហាញស្តីពីលទ្ធផលសិក្សាដែលបានរកឃើញរបស់ WOCAN and NGOs នានាដែលពាក់ព័ន្ធនឹងបញ្ហាយេនឌ័រក្នុងវិស័យព្រៃឈើ<br>• សំណួរ និង ចម្លើយ | កញ្ញា វង្ស សុបញ្ញា |
| 09:45-10:00 | សម្រាកអាហារសម្រន់ | |
| 10:00-11:30 | បទបង្ហាញស្តីពីបទពិសោធន៍យេនឌ័រនិងរេដបូកនៅប្រទេសនានា<br>• សំណួរ និង ចម្លើយ | លោកស្រី រ៉ាងសុខា |
| 11:30- | សម្រាកអាហារថ្ងៃត្រង់ | |

| | | |
|---|---|---|
| 14:00-15:30 | បទបង្ហាញស្តីពីការបញ្ជ្រាបបញ្ហាយេនឌ័រក្នុងវេជបូក<br>• សំណួរ និង ចម្លើយ | លោកសុខ ពិសិដ្ឋ |
| 15:30-15:45 | សម្រាកអាហារសម្រន់ | |
| 15:45-16:45 | ទស្សនាវីដេអូ ស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ<br>• សំណួរ និង ចម្លើយ | លោកសុខ ពិសិដ្ឋ |
| 16:45-17:00 | • សង្ខេបលទ្ធផលសិក្សាថ្ងៃទី២<br>• ការវាយតម្លៃ(ថ្ងៃទី១ និង ថ្ងៃទី២) | លោក លន់ គឹមហ៊ី<br>ក្រុមការងារ |
| | ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៥ | |
| 08:00-08:30 | • វាយការណ៍ចំណុចសំខាន់ៗដែលបានសិក្សាថ្ងៃទី២ | ក្រុមការងារ |
| 08:30-10:00 | ការបង្ហាញ និងណែនាំពីការសាកល្បងប្រើបញ្ជីផ្ទៀងផ្ទាត់បញ្ហាយេនឌ័រ ដើម្បីពិនិត្យមើលការដាក់បញ្ចូលបញ្ហាយេនឌ័រនៅក្នុងសេចក្តីព្រាងយុទ្ធសាស្ត្រវេជបូកជាតិ<br>• ការពិភាក្សាតាមក្រុមសាកល្បងបញ្ជីផ្ទៀងផ្ទាត់បញ្ហាយេនឌ័រ | លោក លន់ គឹមហ៊ី |
| 10:00-10:15 | Coffee Break | |
| 10:15-11:30 | ការបង្ហាញលទ្ធផលនៃការសាកល្បងប្រើបញ្ជីផ្ទៀងផ្ទាត់បញ្ហាយេនឌ័រ | តំណាងក្រុមនីមួយៗ |
| 11:30 | Lunch Break | |
| 14:00-15:30 | ពិធីបិទវគ្គបណ្តុះបណ្តាល<br>• វាយការណ៍លទ្ធផលវាយតម្លៃ(ថ្ងៃទី១ និង ថ្ងៃទី២)<br>• វាយការណ៍សង្ខេបពីលទ្ធផលសិក្សាទាំង៣ថ្ងៃ<br>• មតិចាប់អារម្មណ៍ថ្នាក់ដឹកនាំក្នុងពិធីបិទវគ្គបណ្តុះបណ្តាល | ក្រុមការងារ<br>លោក លន់ គឹមហ៊ី<br>លោក យនសារ៉េត |